# អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

# មគ្គុទ្ទេសក៍ណែនាំប្រើប្រាស់កម្មវិធីទូរស័ព្ទឆ្លាតវៃ

## Cambodia Customs

រៀបចំដោយ÷ នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន

កំណែ÷ ថ្ងៃទី០១ ខែមករា ឆ្នាំ២០២០

## មាតិកា


១. ការណែនាំអំពីកម្មវិធី 3

២. ការចុះឈ្មោះ និងការចូលប្រើប្រាស់កម្មវិធី 3

២.១. ការចុះឈ្មោះប្រើប្រាស់ 3

២.២. ការចូលប្រើប្រាស់កម្មវិធី 4

៣. ការប្រើប្រាស់មុខងារស្វែងរកឯកសាររហ័ស 4

៣.១. ប្រតិវេទន៍គយ 4

៣.២. ប្រតិវេទន៍គយសង្ខេប 5

៣.៣. ប្រតិវេទន៍គយឆ្លងកាត់ 5

៣.៤. បញ្ជីកាទំនិញ 5

៣.៥. បង្កាន់ដៃបង់ប្រាក់ 6

៣.៦. បង្កាន់ដៃពន្ធយានយន្ត 6

៣.៧. បង្កាន់ដៃទទួលប្រាក់កក់ 6

៣.៨. បង្កាន់ដៃបង់ប្រាក់ផ្សេងៗ 7

៣.៩. ប័ណ្ណបញ្ចេញទំនិញពីគយ 7

៣.១០. លិខិតអនុញ្ញាតដឹកជញ្ជូន (ក្រៅពីផលិតផលតេលសិលា) 7

៣.១១. យានយន្តដឹកជញ្ជូនផលិតផលតេលសិលា 8

៣.១២. លិខិតអនុញ្ញាតដឹកជញ្ជូនផលិតផលតេលសិលា 8

៣.១៣. សន្លឹកតែមប្រើ 8

៤. ការប្រើប្រាស់មុខងារស្វែងរកឯកសារតាមរបៀបផ្សេងទៀត 9

៤.១. បង្កាន់ដៃពន្ធយានយន្ត 9

៤.២. លិខិតអនុញ្ញាតដឹកជញ្ជូន 9

៤.២.១. លិខិតអនុញ្ញាតដឹកជញ្ជូនទំនិញ (ក្រៅពីផលិតផលតេលសិលា) 9

៤.២.២. លិខិតអនុញ្ញាតដឹកជញ្ជូនផលិតផលតេលសិលា 10

៤.៣. យានយន្តដឹកជញ្ជូនតេលសិលា 10

៤.៤. សន្លឹកតែមប្រើ 10

៥. របៀបប្ដូរពាក្យសម្ងាត់ និងភ្លេចពាក្យសម្ងាត់ 11

៥.១. របៀបប្ដូរពាក្យសម្ងាត់ 11

៥.២. ភ្លេចពាក្យសម្ងាត់ 11

៦. ការប្រើប្រាស់ PIN Code សុវត្ថិភាព 11

៦.១. ការដាក់កូដ PIN 11

៦.២. ការប្ដូរកូដ PIN 12

៦.៣. ភ្លេចកូដ PIN 12

៧. ការប្រើប្រាស់មីនុយ និងប៊ូតុងផ្សេងទៀត 13

៧.១. អត្រាប្ដូរប្រាក់ 13

៧.២. គេហទំព័ររបស់អគារ 13

៧.៣. ទំព័រហ្វេសប៊ុករបស់អគារ 13

៧.៤. កម្មវិធីតារាងពន្ធគយកម្ពុជា 14

៧.៥. កម្មវិធីនីតិវិធីបញ្ចេញទំនិញពីគយ 14

៧.៦. របៀបប្រើប្រាស់កម្មវិធី 14

៧.៧. ឯកសារជំនួយ 15

៧.៨. ព័ត៌មានទំនាក់ទំនង 15

៧.៩. ព័ត៌មានផ្ទាល់ខ្លួន 15

៧.១០. ការចាកចេញពីកម្មវិធី 16

## ១. ការណែនាំអំពីកម្មវិធី

កម្មវិធីទូរសព្ទដៃ Cambodia Customs ត្រូវបានបង្កើតឡើងដោយក្រុមការងារបច្ចេកទេស របស់នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដើម្បីជួយសម្រួលដល់មន្ត្រីគយនិងរដ្ឋាករក្នុងកិច្ចប្រតិបត្តិការប្រចាំថ្ងៃ ជាពិសេសជួយសម្រួលដល់ការផ្ទៀងផ្ទាត់ឯកសារនានាដែលចេញដោយប្រព័ន្ធស្វ័យប្រវត្តិកម្មគយ។ មុខងារសំខាន់ៗនៅក្នុងកម្មវិធីនេះមាន÷

១. មុខងារស្កែនឯកសាររហ័សដោយប្រើប្រាស់អារកូដ (QR Code) ដែលបច្ចុប្បន្ននេះគ្របដណ្ដប់ឯកសារចំនួន ១៣ ប្រភេទ រួមមាន÷ ប្រតិវេទន៍គយ, ប្រតិវេទន៍គយសង្ខេប, ប្រតិវេទន៍ឆ្លងកាត់, បញ្ជិកាទំនិញក្នុងប្រទេស, បង្កាន់ដៃបង់ប្រាក់, បង្កាន់ដៃពន្ធយានយន្ត, បង្កាន់ដៃទទួលប្រាក់កក់, បង្កាន់ដៃបង់ប្រាក់បន្ថែម, ប័ណ្ណបញ្ចេញទំនិញពីគយ, លិខិតអនុញ្ញាតដឹកជញ្ជូន, លិខិតអនុញ្ញាតដឹកជញ្ជូនផលិតផលតេលសិលា, ប័ណ្ណសម្គាល់មធ្យោបាយដឹកជញ្ជូនផលិតផលតេលសិលា និងសន្លឹកតែមប្រើបារី។

២. មុខងារស្វែងរកឯកសារតាមរបៀបផ្សេងទៀត ដែលមន្ត្រីអាចធ្វើការស្វែងរក ក្នុងករណីដែលមិនអាចស្កែនតាមរយៈអារកូដ (QR Code) ដោយគ្រាន់តែបំពេញនូវលក្ខខណ្ឌមួយចំនួន។

***<u>ដើម្បីទាញយក និងដំឡើងកម្មវិធី÷</u>***

GET IT ON Google Play

Download on the App Store

## ២. ការចុះឈ្មោះ និងការចូលប្រើប្រាស់កម្មវិធី

២.១. ការចុះឈ្មោះប្រើប្រាស់

ដើម្បីអាចប្រើប្រាស់កម្មវិធីនេះបាន លោកអ្នកត្រូវតែជាមន្ត្រីគយនិងរដ្ឋាករ និងត្រូវចុះឈ្មោះប្រើប្រាស់ដោយបំពេញនូវ÷

- លេខទូរស័ព្ទ
- អត្តលេខមន្ត្រីគយ
- ថ្ងៃខែឆ្នាំកំណើត
- និងភ្ជាប់រូបថតប័ណ្ណសម្គាល់មន្ត្រីគយ និងរដ្ឋាករ




បន្ទាប់មកចុចលើប៊ូតុង ***ចុះឈ្មោះ*** ពេលនោះប្រព័ន្ធនឹងផ្ញើសារ SMS នូវ **ឈ្មោះអ្នកប្រើប្រាស់** និង **ពាក្យសម្ងាត់** ចូលក្នុងទូរស័ព្ទដៃដែលលោកអ្នកបានបំពេញនៅខាងដើម។

**ចំណាំ÷ សម្រាប់មន្ត្រីគយនិងរដ្ឋាករដែលមានឈ្មោះប្រើប្រាស់ក្នុងប្រព័ន្ធ e-Customs គឺពុំចាំបាច់ចុះឈ្មោះចូលប្រើប្រាស់ឡើយ គឺអាចប្រើប្រាស់ **ឈ្មោះអ្នកប្រើប្រាស់** និង **ពាក្យសម្ងាត់** ជាមួយប្រព័ន្ធ e-Customs។

២.២. ការចូលប្រើប្រាស់កម្មវិធី

ដើម្បីចូលប្រើប្រាស់កម្មវិធីនេះ អ្នកប្រើប្រាស់ត្រូវបំពេញ ***ឈ្មោះអ្នកប្រើប្រាស់*** និង ***ពាក្យសម្ងាត់*** ឱ្យបានត្រឹមត្រូវ បន្ទាប់មកចុចលើប៊ូតុង ***ចូលប្រើប្រាស់*** ជាការស្រេច។




## **៣. ការប្រើប្រាស់មុខងារស្កេនឯកសាររហ័ស**

មុខងារស្កេនឯកសាររហ័សគ្របដណ្ដប់លើឯកសារចំនួន ១៣ ប្រភេទដូចរៀបរាប់ខាងលើ។ ដើម្បីប្រើប្រាស់មុខងារនេះ អ្នកប្រើប្រាស់គ្រាន់តែចុចលើសញ្ញាយូអារកូដ (ដូចរូប) បន្ទាប់មកអ្នកប្រើប្រាស់ត្រូវដាក់កាមេរ៉ាឱ្យចំពីលើយូអារកូដ (QR Code) ឬបារកូដ (Bar Code) របស់ឯកសារ នោះកម្មវិធីនឹងបង្ហាញលទ្ធផលទៅតាមប្រភេទឯកសារនីមួយៗ។

៣.១. ប្រតិវេទន៍គយ



## ៣.២. ប្រតិវេទន៍គយសង្ខេប




## ៣.៣. ប្រតិវេទន៍គយឆ្លងកាត់




## ៣.៤. បញ្ជិកាទំនិញ



## ៣.៥. បង្កាន់ដៃបង់ប្រាក់




## ៣.៦. បង្កាន់ដៃពន្ធយានយន្ត




## ៣.៧. បង្កាន់ដៃទទួលប្រាក់កក់



## ៣.៨. បង្កាន់ដៃបង់ប្រាក់ផ្សេងៗ




## ៣.៩. ប័ណ្ណបញ្ចេញទំនិញពីគយ




## ៣.១០. លិខិតអនុញ្ញាតដឹកជញ្ជូន (ក្រៅពីផលិតផលតេលសិលា)



## ៣.១១. យានយន្តដឹកជញ្ជូនផលិតផលតេលសិលា




## ៣.១២. លិខិតអនុញ្ញាតដឹកជញ្ជូនផលិតផលតេលសិលា




## ៣.១៣. សន្លឹកតែមប្រើ



## ៤. ការប្រើប្រាស់មុខងារស្វែងរកឯកសារតាមរបៀបផ្សេងទៀត

ក្នុងករណីដែលអ្នកប្រើប្រាស់មិនអាចប្រើមុខងារស្កេនឯកសាររហ័សដោយប្រើប្រាស់យូអារកូដក្រោមហេតុផលមួយចំនួនដូចជា÷

- ឯកសារមិនមានយូអារកូដ
- យូអារកូដរលុប ឬខូចខាត (ដោយផ្នែកឬទាំងស្រុង)
- បញ្ហាកាមេរ៉ាទូរស័ព្ទរបស់អ្នកប្រើប្រាស់ និង/ ឬ
- មូលហេតុសមស្របនានា -ល-

អ្នកប្រើប្រាស់អាចស្វែងរកឯកសារតាមរបៀបផ្សេងទៀត ដោយចុចលើប៊ូតុង ***ស្វែងរកផ្សេងទៀត*** ដូចក្នុងរូបខាងក្រោម÷

### ៤.១. បង្កាន់ដៃពន្ធយានយន្ត

អ្នកប្រើប្រាស់អាចស្វែងរកទិន្នន័យដែលមានក្នុងប្រព័ន្ធរបស់បង្កាន់ដៃពន្ធយានយន្តតាមរយៈ លេខលតាបត្រ, លេខតួ ឬលេខម៉ាស៊ីនរបស់យានយន្ត÷



**ចំណាំ÷ ករណីការស្វែងរកមិនឃើញលទ្ធផល អាចបណ្តាលមកពីហេតុផលផ្សេងៗដូចជា÷

ក. ទិន្នន័យមិនត្រឹមត្រូវ

ខ. អ្នកប្រើប្រាស់បញ្ចូលលក្ខខណ្ឌស្វែងរកមិនត្រឹមត្រូវ

### ៤.២. លិខិតអនុញ្ញាតដឹកជញ្ជូន

ដើម្បីផ្ទៀងផ្ទាត់លិខិតអនុញ្ញាតដឹកជញ្ជូន អ្នកប្រើប្រាស់ត្រូវវាយបញ្ចូលលេខលិខិតអនុញ្ញាត រួចចុចប៊ូតុង ***ស្វែងរក*** ÷

#### ៤.២.១. លិខិតអនុញ្ញាតដឹកជញ្ជូនទំនិញ (ក្រៅពីផលិតផលតេលសិលា)



### ៤.២.២. លិខិតអនុញ្ញាតដឹកជញ្ជូនផលិតផលតេលសិលា




### ៤.៣. យានយន្តដឹកជញ្ជូនតេលសិលា

ដើម្បីផ្ទៀងផ្ទាត់ព័ត៌មានយានយន្តដឹកជញ្ជូនផលិតផលតេលសិលា អ្នកប្រើប្រាស់ត្រូវវាយបញ្ចូលផ្លាកលេខ ឬលេខចុះបញ្ជី រួចចុចប៊ូតុង ***ស្វែងរក*** ៖




### ៤.៤. សន្លឹកតែមប្រើ

ដើម្បីផ្ទៀងផ្ទាត់ព័ត៌មានសន្លឹកតែមប្រើ អ្នកប្រើប្រាស់ត្រូវវាយបញ្ចូលលេខសន្លឹកតែមប្រើ រួចចុចប៊ូតុង ***ស្វែងរក*** ៖



## ៥. របៀបប្តូរពាក្យសម្ងាត់ និងភ្លេចពាក្យសម្ងាត់

### ៥.១. របៀបប្តូរពាក្យសម្ងាត់

ដើម្បីប្តូរពាក្យសម្ងាត់ អ្នកប្រើប្រាស់ត្រូវចូលទៅកាន់ ***ការកំណត់ផ្សេងៗ*** បន្ទាប់មកចុចលើពាក្យ ***ប្តូរពាក្យសម្ងាត់*** ។ នៅផ្ទាំងបន្ទាប់អ្នកប្រើប្រាស់ត្រូវបំពេញក្នុងប្រអប់ ***ពាក្យសម្ងាត់បច្ចុប្បន្ន*** ប្រអប់ ***ពាក្យសម្ងាត់ថ្មី*** និងប្រអប់ ***បញ្ជាក់ពាក្យសម្ងាត់ថ្មី*** បន្ទាប់មកចុចលើប៊ូតុង ***ដាក់ឱ្យដំណើរការ*** ជាការស្រេច។




### ៥.២. ភ្លេចពាក្យសម្ងាត់

ករណីអ្នកប្រើប្រាស់ភ្លេចពាក្យសម្ងាត់ ហើយមិនអាចចូលប្រើប្រាស់កម្មវិធីនេះបាន សូមចុចលើប៊ូតុង ***ភ្លេចពាក្យសម្ងាត់*** បន្ទាប់មកបំពេញ ***លេខទូរស័ព្ទ*** និង ***ថ្ងៃខែឆ្នាំកំណើត*** ហើយចុចប៊ូតុងដាក់ស្នើ នោះកម្មវិធីនឹងបង្ហាញផ្ទាំងមួយទៀតដែលអ្នកប្រើប្រាស់ត្រូវបំពេញលេខកូដដែលប្រព័ន្ធបានផ្ញើសារ SMS ចូលក្នុងទូរស័ព្ទ បន្ទាប់មកបំពេញក្នុងប្រអប់ ***ដាក់ពាក្យសម្ងាត់ថ្មី*** និងប្រអប់ ***បញ្ចូលពាក្យសម្ងាត់ថ្មីដើម្បីបញ្ជាក់*** រួចចុចប៊ូតុង ***កំណត់ពាក្យសម្ងាត់ឡើងវិញ*** ជាការស្រេច។



## ៦. ការប្រើប្រាស់ PIN Code សុវត្ថិភាព

ដើម្បីធានាសុវត្ថិភាពអ្នកប្រើប្រាស់ កម្មវិធីនេះបានបន្ថែមមុខងារ PIN Code សុវត្ថិភាពក្នុងករណីអ្នកប្រើប្រាស់បើកកម្មវិធីនេះទុកចោលយូរ។

### ៦.១. ការដាក់កូដ PIN

ដើម្បីដាក់កូដ PIN អ្នកប្រើប្រាស់ត្រូវចូលទៅកាន់ ***ការកំណត់ផ្សេងៗ*** បន្ទាប់មកទៀតចុចលើពាក្យ ***ដាក់កូដ PIN*** ។ នៅពេលកម្មវិធីបង្ហាញផ្ទាំងបន្ទាប់ អ្នកប្រើប្រាស់ត្រូវបំពេញក្នុងប្រអប់ ***ដាក់កូដ PIN ថ្មី*** និងប្រអប់ ***បញ្ចូលកូដ PIN ដើម្បីបញ្ជាក់*** រួចចុចប៊ូតុង ***ដាក់ឱ្យដំណើរការ*** ជាការស្រេច។




៦.២. ការប្តូរកូដ PIN

ករណីអ្នកប្រើប្រាស់ចង់ប្តូរកូដ PIN សូមចូលទៅកាន់ ***ការកំណត់ផ្សេងៗ*** បន្ទាប់មកទៀតចុចលើពាក្យ ***ប្តូរកូដ PIN*** ។ នៅពេលកម្មវិធីបង្ហាញផ្ទាំងបន្ទាប់ អ្នកប្រើប្រាស់ត្រូវបំពេញក្នុងប្រអប់ ***ដាក់កូដ PIN បច្ចុប្បន្ន*** ប្រអប់ ***ដាក់កូដ PIN ថ្មី*** និងប្រអប់ ***បញ្ចូលកូដ PIN ថ្មីដើម្បីបញ្ជាក់*** រួចចុចប៊ូតុង ***ដាក់ឱ្យដំណើរការ*** ជាការស្រេច។




៦.៣. ភ្លេចកូដ PIN

ករណីអ្នកប្រើប្រាស់ភ្លេចកូដ PIN សូមចូលទៅកាន់ ***ការកំណត់ផ្សេងៗ*** បន្ទាប់មកទៀតចុចលើពាក្យ ***ភ្លេចកូដ PIN*** ។ បន្ទាប់មកទៀតកម្មវិធីនឹងចេញសារបញ្ជាក់ ហើយអ្នកប្រើប្រាស់គ្រាន់តែចុចលើប៊ូតុង ***យល់ព្រម*** ពេលនោះកម្មវិធីនិងចាកចេញដើម្បីលុបលេខកូដ PIN ចោល។



# ៧. ការប្រើប្រាស់មីនុយ និងប៊ូតុងផ្សេងទៀត

## ៧.១. អត្រាប្ដូរប្រាក់

នៅលើផ្ទាំង Dashboard របស់កម្មវិធីនេះ មានបង្ហាញនូវអត្រាប្ដូរប្រាក់ពីប្រាក់ដុល្លារអាមេរិកមកប្រាក់រៀលខ្មែរ។ ករណីអ្នកប្រើប្រាស់ចង់មើលអត្រាប្ដូរប្រាក់របស់ប្រទេសផ្សេងទៀត អ្នកប្រើប្រាស់គ្រាន់តែចុចលើអត្រាប្ដូរប្រាក់នោះកម្មវិធីនិងបង្ហាញលម្អិតដូចខាងក្រោម÷




## ៧.២. គេហទំព័ររបស់អគរ

ដើម្បីចូលទៅកាន់គេហទំព័ររបស់អគរ អ្នកប្រើប្រាស់គ្រាន់តែចុចលើប៊ូតុង ***គេហទំព័រ*** ជាការស្រេច។




## ៧.៣. ទំព័រហ្វេសប៊ុករបស់អគរ

ដើម្បីចូលទៅកាន់ទំព័រហ្វេសប៊ុករបស់អគរ អ្នកប្រើប្រាស់គ្រាន់តែចុចលើប៊ូតុង ***ទំព័រហ្វេសប៊ុក*** ជាការស្រេច។



## ៧.៤. កម្មវិធីតារាងពន្ធគយកម្ពុជា

ដើម្បីចូលទៅកាន់កម្មវិធីតារាងពន្ធគយកម្ពុជា អ្នកប្រើប្រាស់គ្រាន់តែចុចលើមីនុយ បន្ទាប់មកទៀតចុចលើពាក្យ ***តារាងពន្ធគយកម្ពុជា*** ជាការស្រេច។







## ៧.៥. កម្មវិធីនីតិវិធីបញ្ចេញទំនិញពីគយ

ដើម្បីចូលទៅកាន់កម្មវិធីនីតិវិធីបញ្ចេញទំនិញពីគយ អ្នកប្រើប្រាស់គ្រាន់តែចុចលើមីនុយ បន្ទាប់មកទៀតចុចលើពាក្យ ***នីតិវិធីបញ្ចេញទំនិញពីគយ*** ជាការស្រេច។







## ៧.៦. របៀបប្រើប្រាស់កម្មវិធី

ដើម្បីចូលទៅមើលរបៀបប្រើប្រាស់កម្មវិធីនេះ អ្នកប្រើប្រាស់គ្រាន់តែចុចលើមីនុយ បន្ទាប់មកទៀតចុចលើពាក្យ ***របៀបប្រើប្រាស់*** ជាការស្រេច។






### ៧.៧. ឯកសារជំនួយ

ដើម្បីចូលទៅមើលឯកសារជំនួយផ្សេងៗ ជាពិសេសលិខិតបទដ្ឋានគតិយុត្តិនានាជាធរមាន អ្នកប្រើប្រាស់គ្រាន់តែចុចលើមីនុយ បន្ទាប់មកទៀតចុចលើពាក្យ ***ឯកសារជំនួយ*** ពេលនោះកម្មវិធីនឹងបង្ហាញនូវលិខិតបទដ្ឋានគតិយុត្តិជាច្រើន។ អ្នកប្រើប្រាស់គ្រាន់តែចុចលើលិខិតបទដ្ឋានគតិយុត្តិណាមួយ ពេលនោះកម្មវិធីនឹងបើកលិខិតបទដ្ឋានគតិយុត្តិនោះភ្លាម។



### ៧.៨. ព័ត៌មានទំនាក់ទំនង

ដើម្បីចូលទៅមើលព័ត៌មានទំនាក់ទំនង អ្នកប្រើប្រាស់គ្រាន់តែចុចលើមីនុយ បន្ទាប់មកទៀតចុចលើពាក្យ ***ព័ត៌មានទំនាក់ទំនង*** ជាការស្រេច។



### ៧.៩. ព័ត៌មានផ្ទាល់ខ្លួន

ដើម្បីចូលទៅមើលព័ត៌មានផ្ទាល់ខ្លួន អ្នកប្រើប្រាស់គ្រាន់តែចុចលើមីនុយ បន្ទាប់មកទៀតចុចលើពាក្យ ***ព័ត៌មានផ្ទាល់ខ្លួន*** ឬ ចុចលើរូបសញ្ញាអ្នកប្រើប្រាស់នៅក្នុង Dashboard នៃកម្មវិធីនេះជាការស្រេច។



### ៧.១០. ការចាកចេញពីកម្មវិធី

ដើម្បីចាកចេញពីកម្មវិធី (Logout) អ្នកប្រើប្រាស់គ្រាន់តែចូលទៅកាន់ព័ត៌មានផ្ទាល់ខ្លួន បន្ទាប់មកទៀតចុចលើពាក្យ ***ចាកចេញ*** ពេលនោះប្រព័ន្ធនឹងសួរបញ្ជាក់។ អ្នកប្រើប្រាស់គ្រាន់តែចុចលើប៊ូតុងយល់ព្រមជាការស្រេច។




**សូមអរគុណ៕**